ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខៈ ០០២៧.៧៩.../គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី០៤.. ខែ.មករា.. ឆ្នាំ២០១៧

**គោរពជូន**

**ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ៖** ស្តីពីកាលបរិច្ឆេទនៃការបិទការបញ្ចូលទិន្នន័យឆ្នាំ២០១៦ និងការបើកបញ្ចូលទិន្នន័យឆ្នាំ២០១៧ ក្នុងប្រព័ន្ធតាមដាន និងវាយតម្លៃផ្ទៃក្នុងក្រុង ស្រុក ខណ្ឌ ។

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមអភិបាលមេត្តាជ្រាបថា លេខាធិការដ្ឋានគ.ជ.អ.ប បានពិនិត្យឃើញថាការបញ្ចូលទិន្នន័យរបស់ក្រុង ស្រុក ខណ្ឌ គោលដៅទាំង៤៧ ទៅក្នុងប្រព័ន្ធតាមដាន និងវាយតម្លៃផ្ទៃក្នុងក្រុង ស្រុក ខណ្ឌ នៅក្នុងឆ្នាំ២០១៦នេះ ទទួលបានលទ្ធផលគួរអោយកត់សម្គាល់។ ដើម្បីត្រៀមបញ្ចូលទិន្នន័យឆ្នាំ២០១៧ លេខាធិការដ្ឋាន នឹងបិទការបញ្ចូលទិន្នន័យឆ្នាំ២០១៦ ត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ។ ប្រព័ន្ធនឹងបើកសម្រាប់ការបញ្ចូលទិន្នន័យថ្មីឆ្នាំ២០១៧ ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧។ម្យ៉ាងវិញទៀត សម្រាប់ការអនុវត្តប្រព័ន្ធឆ្នាំ២០១៧ លេខាធិការដ្ឋាន គ.ជ.អ.ប សូមស្នើរាជធានី ខេត្ត ធ្វើការជ្រើសរើស និងកំណត់ក្រុង ស្រុក ខណ្ឌគោលដៅថ្មី យ៉ាងតិចចំនួន០១បន្ថែមទៀត ដើម្បីអនុវត្តប្រព័ន្ធនេះ។ ទន្ទឹមនឹងនោះ ដើម្បីធានាការអនុវត្តប្រព័ន្ធប្រកបដោយប្រសិទ្ធិភាព រាជធានី ខេត្ត គួរផ្តល់វគ្គបណ្តុះបណ្តាលដល់ក្រុង ស្រុក ខណ្ឌ គោលដៅថ្មី និងពង្រឹងសមត្ថភាពដល់ក្រុង ស្រុក ខណ្ឌ គោលដៅចាស់ផងដែរ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជូនដំណឹងដល់ក្រុង ស្រុក ខណ្ឌ និងជ្រើសរើសក្រុង ស្រុក ខណ្ឌ គោលដៅថ្មីតាមការគួរ។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**ប្រធានលេខាធិការដ្ឋានគ.ជ.អ.ប**
អនុប្រធានប្រចាំការ

ង៉ាន់ ចំរើន

សូមភ្ជាប់ជាមួយ៖
បញ្ជីក្រុងស្រុកខណ្ឌគោលដៅចាស់
នៃប្រព័ន្ធតាមដាន វាយតម្លៃផ្ទៃក្នុងក្រុង ស្រុក ខណ្ឌ
ចម្លងជូន៖
អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ (ដើម្បីជូនជ្រាប)

# បញ្ជីក្រុងស្រុកខណ្ឌគោលដៅនៃប្រព័ន្ធតាមដាន វាយតម្លៃផ្ទៃក្នុងក្រុងស្រុកខណ្ឌ

| ល.រ | ខេត្ត/រាជធានី | ឈ្មោះក្រុង/ស្រុក/ខណ្ឌ |
|---|---|---|
| ១ | បន្ទាយមានជ័យ | ស្រុកថ្មពួក |
| ២ | បាត់ដំបង | ស្រុករតនៈមណ្ឌល |
| ៣ | កំពង់ចាម | ស្រុកបាធាយ ស្រុកជើងព្រៃ ក្រុងកំពង់ចាម ស្រុកកំពង់សៀម និងស្រុកស្រីសន្ធរ |
| ៤ | កំពង់ឆ្នាំង | ស្រុករលាប្អៀរ |
| ៥ | កំពង់ស្ពឺ | ក្រុងច្បារមន |
| ៦ | កំពង់ធំ | ស្រុកកំពង់ស្វាយ ក្រុងស្ទឹងសែន ស្រុកប្រាសាទបល្ល័ង្គ ស្រុកប្រាសាទសំបូរ ស្រុកសន្ទុក និងស្រុកស្ទោង |
| ៧ | កំពត | ស្រុកទឹកឈូ និងក្រុងកំពត |
| ៨ | កណ្ដាល | ស្រុកខ្សាច់កណ្ដាល និងស្រុកស្អាង |
| ៩ | កោះកុង | ស្រុកស្រែអំបិល |
| ១០ | ក្រចេះ | ក្រុងក្រចេះ |
| ១១ | មណ្ឌលគីរី | ក្រុងសែនមនោរម្យ |
| ១២ | ភ្នំពេញ | ខណ្ឌដូនពេញ ខណ្ឌ៧មករា ខណ្ឌទួលគោក ខណ្ឌសែនសុខ ខណ្ឌពោធិ៍សែនជ័យ និងខណ្ឌជ្រោយចង្វារ |
| ១៣ | ព្រះវិហារ | ស្រុករវៀង ស្រុកសង្គមថ្មី និងស្រុកត្បែងមានជ័យ |
| ១៤ | ព្រៃវែង | ក្រុងព្រៃវែង |
| ១៥ | ពោធិ៍សាត់ | ស្រុកកណ្ដៀង ស្រុកក្រគរ ស្រុកភ្នំក្រវាញ និងក្រុងពោធិ៍សាត់ |
| ១៦ | រតនៈគីរី | ក្រុងបានលុង |
| ១៧ | សៀមរាប | ក្រុងសៀមរាប |
| ១៨ | ព្រះសីហនុ | ក្រុងព្រះសីហនុ |
| ១៩ | ស្ទឹងត្រែង | ស្រុកថាឡាបរិវ៉ាត់ |
| ២០ | ស្វាយរៀង | ស្រុកស្វាយជ្រំ |
| ២១ | តាកែវ | ស្រុកទ្រាំង |
| ២២ | ឧត្ដរមានជ័យ | ក្រុងសំរោង |
| ២៣ | កែប | ក្រុងកែប និងស្រុកដំណាក់ចង្អើរ |
| ២៤ | ប៉ៃលិន | ស្រុកសាលាក្រៅ |
| ២៥ | ត្បូងឃ្មុំ | ក្រុងសួង |